បន្ទាយស្រី

BANTEAY SREI

# វគ្គបណ្តុះបណ្តាលស្តីពី លើកកម្ពស់នៃ
# ការយល់ដឹងអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ

# ណែនាំឲ្យស្គាល់គ្នា

❖ប្រាប់ពីឈ្មោះ

❖តួនាទី និងស្ថាប័ន

# សំណួរសាកល្បងមុនវគ្គ



# ប្រធានបទទី ១

# គោលគំនិតទូទៅនៃយេនឌ័រ

# ទស្សនៈ និងការយល់ឃើញ អំពីពាក្យយេនឌ័រ ក្នុងសង្គមបច្ចុប្បន្ន

១ សមតាពរវាងបុរស និងស្ត្រី

២ ការលើកកម្ពស់ស្ថានភាពស្ត្រី ឬសិទ្ធិស្ត្រី

៣ ជាភេទ (ភេទប្រុស ឬភេទស្រី)

៤ ផ្នត់គំនិត ឬការកំណត់របស់សង្គមមកលើបុរស ស្ត្រី រួមទាំងជនមានពិការភាព

# អត្ថន័យ និងចំណាក់ចំណងយេនឌ័រ



# អត្ថន័យ និងទំនាក់ទំនងយេនឌ័រ





តើសង្គម គ្រួសារ និងសហគមន៍ មានការរំពឹងទុក និងប្រព្រឹត្តដូចម្តេចខ្លះ ចំពោះកូនប្រុស និងកូនស្រី?
(ចាប់ពីពេលកើតរហូតដល់ពេញវ័យ)

# ការរំពឹងទុក និងការប្រព្រឹត្តរបស់គ្រួសារ និងសហគមន៍ទាំងនេះ

ទារក



ទារិកា



បញ្ជាក់ពី
ភេទប្រុស និងភេទស្រី

ក្មេងប្រុស



ក្មេងស្រី



រៀនពីឥរិយាបថ និង
ការប្រព្រឹត្តផ្សេងៗគ្នា

បុរស



ស្ត្រី



ការបែងចែកការងារ

# វិសមភាពយេនឌ័រ

**អំណាចតិចតួច**

**អំណាចច្រើន**



១. ការធ្វើសេចក្ដីសម្រេច

២. ទទួលបានប្រាក់ខែខ្ពស់

៣. ទទួលបានការអប់រំ

៤. ទទួលបានការគោរព

៥.មានតួនាទីគ្រប់គ្រងក្នុងសហគមន៍

៦.សិទ្ធក្នុងការធ្វើសេចក្ដីសម្រេចក្នុងគ្រួសារ

៧.មានការងារធ្វើនៅក្នុងសង្គម

៨. មានជម្រើសច្រើន

៩. ការទទួលបានសុវត្ថិភាព





តើត្រូវធ្វើដូច
ម្តេចខ្លះ ដើម្បី
កែលម្អនូវការ
រំពឹងទុក និង
ការប្រព្រឹត្តមក
លើកូនប្រុស
កូនស្រី បុរស
និងស្ត្រី?

ដូចនេះ គ្រួសារ សហគមន៍ និងសង្គម ត្រូវរួមគ្នា៖

- ជម្រុញ និងផ្តល់ឱកាសដល់កូនប្រុសកូនស្រី បុរស និងស្ត្រី ទទួលបានឱកាសស្មើគ្នា ក្នុងការការអប់រំ ការថែទាំ និងទំនុកបំរុងកិច្ចការពារផ្សេងៗ។
- បង្កើនភាពអង់អាច សមត្ថភាព និងលទ្ធភាពឲ្យស្ត្រីមានឱកាសចូលរួមការងារអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងការធ្វើសេចក្តីសម្រេចក្នុងគ្រួសារសហគមន៍ និងសង្គម។







# ភាពខុសគ្នារវាងភេទ និងយេនឌ័រ

| ភេទ | យេនឌ័រ |
| --- | --- |
| លក្ខណៈជីវសាស្ត្រ | កំណត់ដោយសង្គម |
| មិនអាចកែប្រែ និងផ្លាស់ប្តូរបាន | អាចកែប្រែ និងផ្លាស់ប្តូរបាន |
| ❖ មានតែស្ត្រីទេ អាចពរពោះបាន និងបំបៅកូន ដោយទឹកដោះម្តាយ និងមានតែបុរសទេអាចផ្តល់មេជីវិត។ | ❖ ស្ត្រី និងបុរស អាចធ្វើជាវិស្វករ និងអ្នកគ្រប់គ្រង បានដូចគ្នា<br>❖ ស្ត្រី និងបុរស អាចធ្វើការផ្ទះបានដូចគ្នា |

# ប្រធានបទ២

# សមភាពយេនឌ័រ សមធម៌យេនឌ័រ និងវិធានការក្នុងការដោះស្រាយវិសមភាពយេនឌ័រ

តាមការយល់
ឃើញរបស់
លោក លោកស្រី
តើសមធម៌យេន
ឌ័រមានន័យ
ដូចម្តេច



តាមការយល់
ឃើញរបស់
លោក លោក
ស្រី តើសមភាព
យេនឌ័រមាន
ន័យដូចម្តេច

# ខ្លឹមសារសង្ខេប សមភាព និងសមធម៌យេនឌ័រ

## សមភាពយេនឌ័រ

ជាគោលការណ៍គ្មានការរើសអើងទៅលើភេទណាមួយ

មានគោលដៅដើម្បីឱ្យបុរស-ស្ត្រី កូនប្រុស-កូនស្រី មានឱកាស តម្លៃ ធនធាន និងផលប្រយោជន៍ដូចៗគ្នា ដោយពិតប្រាកដនៅក្នុងគ្រួសារ សហគមន៍ ស្ថាប័ន និងសង្គម

## សមធម៌យេនឌ័រ

ជាគោលការណ៍ យុទ្ធសាស្ត្រ មធ្យោបាយ ឬវិធានការវិជ្ជមានដែលបង្កលក្ខណៈ ឬផ្តល់ឱកាសដល់បុគ្គល ឬក្រុមណាមួយនៃភេទ (បុរស-ស្រី)

ក្នុងការកាត់បន្ថយគម្លាត និង

ដើម្បីឈានទៅសម្រេចសមភាពយេនឌ័រ

- ការបង្កើនភាពអង់អាចដល់ស្ត្រី និងក្មេងស្រី

ខ្លឹមសារទូទៅ

# សមភាព និងសមធម៌យេនឌ័រ








សូមមើលរូបទាំងបីនេះ
និងបកស្រាយ អំពីសមភាព និងសមធម៌ សម្រាប់ទាំងអស់គ្នា

# វិធានការមួយចំនួនក្នុងការដោះស្រាយវិសមភាពយេនឌ័រ


ដើម្បីយុត្តិធម៌ អ្នកទាំងអស់គ្នាត្រូវធ្វើ
លំហាត់ដូចគ្នា តាមរយៈការឡើង
ដើមឈើ

# វិធានការដូចគ្នា

- វិធានការនេះ មិនបានខ្វល់ពីភាពខុសគ្នាតាមជីវសាស្ត្រ និងយេនឌ័ររវាងពួកគាត់ទាំងពីរភេទ និងមិនបានផ្តល់ផលប្រយោជន៍ដល់ស្ត្រីទេ ព្រោះមិនបានពិចារណាបញ្ហាយេនឌ័រឡើយ។
- ដោយសារតែមិនទទួលបានផលប្រយោជន៍តាមរយៈមុខងារយេនឌ័រ ការទទួលខុសត្រូវច្រើន និងកង្វះលទ្ធភាពប្រើប្រាស់ធនធាន មានតែស្ត្រីមួយចំនួនតូចប៉ុណ្ណោះដែលអាចប្រកួតប្រជែងជាមួយបុរសដោយពេញលេញបាន។





# វិធានការសមភាពនៃលទ្ធផល

វិធានការនេះទទួលស្គាល់ពីភាពខុសគ្នារវាងបុរស និងស្ត្រី ដោយបង្ហាញនូវសារសំខាន់នៃសមភាពសម្រាប់អ្នកទាំងនោះ

សំគាល់៖ វិធានការនេះ ជាទស្សនវិស័យមួយដែលត្រឹមត្រូវ

# វិធានការដាក់លាក់ក្នុងការយកចិត្តទុកដាក់ និងការពារដល់ស្ត្រី

ការឧបត្ថម្ភជាប្រាក់ ឬថ្នាំពេទ្យ

ការការពារភាពមានការងារធ្វើ និងគ្មានការរើសអើង

ការសម្រាកលំហែលមាតុភាព

ការការពារសុខភាព

**ការការពារមាតុភាព**

**ការផ្តល់លក្ខខណ្ឌពិសេស សម្រាប់ស្ត្រីមានផ្ទៃពោះ និងម្តាយមានកូនខ្ចី**

ការសម្រាកបំបៅកូន

ច្បាប់សម្រាប់ឪពុកឈប់សម្រាប់មើលថែទាំកូន

ការរៀបចំម៉ោងសម្រាប់ធ្វើការ

ការហាមប្រាមការធ្វើការពេលយប់ និងការធ្វើការងារដែលមានគ្រោះថ្នាក់

# ប្រធានបទទី ៣

# តម្រូវការយេនឌ័រ



តើបុរស និងស្ត្រី មានតម្រូវការអ្វីខ្លះ សម្រាប់ការរស់នៅប្រចាំថ្ងៃ?

## ពិភាក្សាក្រុម

សូមបែងចែកជាពីក្រុម៖

១.ក្រុមបុរស ពិភាក្សា តើតម្រូវការប្រចាំថ្ងៃអ្វីខ្លះដែលបុរសត្រូវការសម្រាប់ការរស់នៅប្រចាំថ្ងៃ?

២.ក្រុមស្ត្រី ពិភាក្សា តើតម្រូវការប្រចាំថ្ងៃអ្វីខ្លះ ដែលស្ត្រីត្រូវការសម្រាប់ការរស់នៅប្រចាំថ្ងៃ?

# តម្រូវការយេនឌ័រ

## ១.តម្រូវការយេនឌ័រចំពោះមុខ

គឺជាតម្រូវការជាក់ស្តែងបន្ទាន់ ដើម្បីឆ្លើយតបការទទួលខុសត្រូវ ក្នុងការដោះស្រាយជីវភាពរស់ នៅប្រចាំថ្ងៃរបស់ស្ត្រី-បុរស។

ឧទាហរណ៍៖ ជម្រក ទឹកស្អាត មង្គន់អនាម័យ .....។ល។

## ២.តម្រូវការយេនឌ័រជាយុទ្ធសាស្ត្រ

គឺជាតម្រូវការដែលទាក់ទងទៅនឹង សកម្មភាពបង្កើនការចូលរួមរបស់ ស្ត្រី-បុរស ក្នុងការផ្លាស់ប្តូរកែប្រែ ឋានៈតួនាទី។

ឧទាហរណ៍៖គ្រូបង្រៀន ថ្នាក់ដឹកនាំ ភូមិ ឃុំ .....។ល។

# ភាពខុសគ្នារវាងតម្រូវការយេនឌ័រចំពោះមុខ តម្រូវការយេនឌ័រជាយុទ្ធសាស្ត្រ និងសារៈប្រយោជន៍

| តម្រូវការយេនឌ័រចំពោះមុខ | តម្រូវការយេនឌ័រជាយុទ្ធសាស្ត្រ |
|---|---|
| ❖ ដោះស្រាយតម្រូវការបុរស-ស្ត្រីបានមួយចំនួនប៉ុណ្ណោះ ទាក់ទងនឹងតម្រូវការជីវភាពប្រចាំថ្ងៃ | ❖ ដោះស្រាយតម្រូវការបុរស-ស្ត្រីទាក់ទងនឹងការផ្លាស់ប្តូឋានៈ តួនាទីរបស់ពួកគាត់ |
| សារៈប្រយោជន៍នៃតម្រូវការយេនឌ័រចំពោះមុខ | សារៈប្រយោជន៍នៃតម្រូវការយេនឌ័រជាយុទ្ធសាស្ត្រ |
| ❖ បង្កើននូវការងារសិប្បកម្ម ឬមុខរបរផ្សេងៗ | ❖ វិធានការលើកកម្ពស់ឋានៈ តួនាទី និងការងារ |

# ឧទាហរណ៍

| ប្រភេទការងារ | តម្រូវការយេនឌ័រចំពោះមុខ | តម្រូវការយេនឌ័រជាយុទ្ធសាស្រ្ត |
|---|---|---|
| បណ្តុះបណ្តាលជំនាញកាត់ដេរ | | |
| មានសាលារៀននៅតាមភូមិ | | |
| មានមណ្ឌលសុខភាពនៅសហគមន៍ | | |
| មានសិទ្ធកាន់កាប់ដីធ្លី | | |
| បង្កើនសមាសភាពថ្នាក់ធ្វើសេក្តីសម្រេច | | |
| ផ្តល់ឥណទានដល់ស្រ្តី | | |
| បណ្តុះបណ្តាលជាងជួសជុលម៉ូតូ | | |

# ប្រធានបទ៤

# ការយល់ដឹងអំពី

# អំពើហិង្សាទាក់ទងនឹងយេនឌ័រ

# និងផលវិបាក

- តើអំពើហិង្សាទាក់ទងនឹងយេនឌ័រ មានប៉ុន្មានប្រភេទ?

# ប្រភេទអំពើហិង្សាទាក់ទងនឹងយេនឌ័រមាន៖

- អំពើហិង្សាផ្លូវកាយ
- អំពើហិង្សាផ្លូវចិត្ត
- អំពើហិង្សាផ្លូវភេទ
- អំពើហិង្សាផ្នែកជីវភាពសេដ្ឋកិច្ច

# ពិភាក្សាក្រុមតូច

.បែកចែកជា ៤ ក្រុម

.ក្រុមនីមួយៗ ត្រូវគូររូបនៅលើក្រដាសផ្ទាំងធំ (ប្រើគ្រូល័រព័ណ៌ផ្សេងៗ)

.គូររូប ទៅលើសកម្មភាពណាដែលអ្នកបានឃើញ និងជួបប្រទះ ទាក់ទងនឹងអំពើហិង្សាលើស្ត្រី និងកុមារ និងស្ត្រីពិការ

.រយៈពេលនៃការពិភាក្សា ១០នាទី

.ក្រុមនីមួយត្រូវឡើងបង្ហាញពីសកម្មភាពរូបភាពនីមួយៗ

- **ឧទាហរណ៍៖**
- រុញ ច្រាន វាយដំ ទាត់ធាក់  ទះកំផ្លៀង វាយនឹងវត្ថុ គប់នឹងវត្ថុ  អំពើផ្សេងទៀតដែលបង្កគ្រោះថ្នាក់... ។ល។



ឧទាហរណ៍ពីអាកប្បកិរិយាមួយចំនួនដូចជា ៖

ស្រែក ជេរ ប្រមាថ ធ្វើឲ្យអាម៉ាស់ រិះគន់

គំរាមកំហែង ការប្រើពាក្យអសុរស ...។ល។



# ឧទាហរណ៍៖

ការបង្ខំឱ្យរួមភេទ ការចាប់រំលោភ បទប្រទូស្តកេរ្ត៍ខ្មាស ការបង្ខំឱ្យរៀបការ ឬរុកកួនផ្លូវភេទ...។ល។



## ឧទាហរណ៍៖

ការបដិសេធមិនឲ្យដៃគូគ្រប់គ្រងធនធានសំខាន់ៗដូចជា ៖

- ការមិនផ្តល់ថវិកា បំផ្លិចបំផ្លាញទ្រព្យ
- ការមិនជួយផ្នែកហិរញ្ញវត្ថុ
- ការបិតសិទ្ធិសេរីភាពក្នុងការរកប្រាប់ចំណូល





# ប្រភេទ/សកម្មភាពនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ



# មូលហេតុដែលនាំឱ្យហិង្សា

.ចង់បានអំណាច និងការត្រួតត្រាលើសមាជិកគ្រួ

.ចង់ឱ្យគេគោរពកោតខ្លាច និងធ្វើតាមតម្រូវការ

.ចង់បង្ហាញថាខ្លួនជាមនុស្សខ្លាំងពូកែ

.ខ្វះវិធីគ្រប់គ្រងកំហឹងរបស់ខ្លួន

.ខ្វះទឹកចិត្តមេត្តា ឬអធ្យាស្រ័យដល់អ្នកដ៏ទៃ...



# កត្តាជម្រុញ

**កត្តាជំរុញ**គឺជាកត្តាដែលជំរុញឲ្យមានអំពើហិង្សាលើស្ត្រី ឬបង្កើនហានិភ័យនៃអំពើហិង្សាលើស្ត្រី និងជះឥទ្ធិពលលើប្រភេទ និងទំហំនៃអំពើហិង្សាលើស្ត្រីក្នុងគ្រប់មជ្ឈដ្ឋាន។ កត្តាជំរុញមិនបង្កឲ្យមានអំពើហិង្សាលើស្ត្រីឡើយ ទោះបីជាវាពាក់ព័ន្ធនឹងអំពើមួយចំនួននៃការប្រព្រឹត្តអំពើហិង្សាលើស្ត្រីក៏ដោយ។

**ឧទាហរណ៍៖**

- ការប្រើប្រាស់គ្រឿងញៀន ឬគ្រឿងស្រវឹង ជាកត្តាជំរុញ ប៉ុន្តែមិនមែនអ្នកសេពគ្រឿងញៀន ឬគ្រឿងស្រវឹងទាំងអស់សុទ្ធតែវាយប្រពន្ធរបស់ខ្លួន ឬចាប់រំលោភស្ត្រីឡើយ។
- ភាពក្រីក្រ អវិជ្ជា ប្រច័ណ្ឌ ...ជាកត្តាជំរុញ ប៉ុន្តែមិនមែនស្ត្រី និងក្មេងស្រីក្រីក្រទាំងអស់សុទ្ធតែទទួលរងការបំពានផ្លូវភេទ ឬត្រូវធ្វើការងារផ្លូវភេទឡើយ។

កត្តាជំរុញជាច្រើនអាចត្រូវបានលុបបំបាត់ ឬកាត់បន្ថយច្រើនតាមរយៈសកម្មភាពទប់ស្កាត់។




ផ្លែឈើ

– ផលវិបាក

មែកឈើ:
ប្រភេទនៃហិង្សា

ដើម:អ្នកដឹកនាំហេតុ

កត្តាជំរុញ

ដើមហេតុ

# ល្បែងថាមពលៈតើលោក លោកស្រីបានឃើញអ្វី ?













# គោលនយោបាយ និងច្បាប់ពាក់ព័ន្ធដើម្បីផ្តល់កិច្ចការពារដល់ស្ត្រីរងគ្រោះ និងជនមានពិការភាព










# ផែនការយុទ្ធសាស្ត្រ នារីរតនៈទី៥
# ទិដ្ឋភាពទូទៅ

# ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ ២០១៩-២០២៣

## ដើម្បីសម្រេចសមភាពយេនឌ័រ និងភាពអង់អាចរបស់ស្ត្រីនិងក្មេងស្រីគ្រប់រូបនៅកម្ពុជា

### ក្របខណ្ឌការបញ្ជ្រាបយេនឌ័រ

ក្របខណ្ឌច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ កម្មវិធីជាតិ និងការផ្លាស់ប្តូរឥរិយាបថជាសាធារណៈ

| យុទ្ធសាស្ត្រទី ១ | យុទ្ធសាស្ត្រទី ២ | យុទ្ធសាស្ត្រទី ៣ | យុទ្ធសាស្ត្រទី ៤ | យុទ្ធសាស្ត្រទី ៥ | យុទ្ធសាស្ត្រទី ៦ |
|---|---|---|---|---|---|
| ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី | ការលើកកម្ពស់ការអប់រំរបស់ស្ត្រី និងក្មេងស្រី | ការលើកកម្ពស់សុខភាពរបស់ស្ត្រី និងក្មេងស្រី | កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងក្មេងស្រី | ភាពជាអ្នកដឹកនាំរបស់ស្ត្រីក្នុង វិស័យសាធារណៈ និងនយោបាយ | ការបញ្ជ្រាបយេនឌ័រ ក្នុងការប្រែប្រួល អាកាសធាតុ |

### ការពង្រឹងសមត្ថភាព និងអភិបាលស្ថាប័ន

ការអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីវិមជ្ឈការនិងវិសហមជ្ឈការ ការធ្វើទំនើបកម្មស្ថាប័ន អភិវឌ្ឍន៍ធនធានមនុស្ស ប្រព័ន្ធតាមដាននិងវាយតម្លៃ ការគ្រប់គ្រងព័ត៌មាន និងកិច្ចសហប្រតិបត្តិការ

# គ្របខណ្ឌការបញ្ជ្រាបយេនឌ័រ

## គ្របខណ្ឌច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ កម្មវិធីជាតិ និងការផ្លាស់ប្តូរឥរិយាបថជាសាធារណៈ

1. ពង្រីកកម្មវិធី**សិក្សាស្រាវជ្រាវ និងប៉ាន់ប្រមាណ**ស្ថានភាពយេនឌ័រ ព្រមទាំងការរៀបចំនិងអនុវត្តគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ និងកម្មវិធីតាមវិស័យ។
2. បញ្ជ្រាបយេនឌ័រ ក្នុងក្របខណ្ឌ**ផែនការយុទ្ធសាស្ត្រតាមវិស័យ និងកម្មវិធីជាតិ** រួមទាំងការងារកំណែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីវិមជ្ឈការនិងវិសហមជ្ឈការ និងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
3. **ពង្រឹងសមត្ថភាព**របស់យន្តការបញ្ជ្រាបយេនឌ័រនៅគ្រប់កម្រិត ថ្នាក់ជាតិនិងក្រោមជាតិ
4. ពង្រឹងប្រព័ន្ធ និងយន្តការ**តាមដានត្រួតពិនិត្យ និងវាយតម្លៃ**លើការបញ្ជ្រាបយេនឌ័រតាមវិស័យ។
5. បង្កើន**ការយល់ដឹងជាសាធារណៈ និងការគាំទ្រ**លើសមភាពយេនឌ័រ រួមទាំងការផ្លាស់ប្តូរឥរិយាបថ និងផ្នត់គំនិតអវិជ្ជមានរបស់សង្គមដែលរើសអើងលើស្ត្រីនិងក្មេងស្រីគ្រប់រូបភាព
6. **ចងក្រងមេរៀន**បទពិសោធន៍ និងឧត្តមានុវត្តន៍នានា ព្រមទាំងចែករំលែកនិងផ្លាស់ប្តូរបទពិសោធន៍

# ផែនការសកម្មភាពជាតិស្តីពី
# ការទប់ស្កាត់អំពើហិង្សាលើស្ត្រី



# និន្នាការរួមនៃNAVPAW 2019 - 2023




**សារបាន**

- ឯកសារគតិយុត្ត និងគោលនយោបាយជាតិ
- គោលនយោបាយអន្តរជាតិ
- ការវិភាគលើស្ថានភាពបច្ចុប្បន្ន

**អាទិភាព**

- អំពើហិង្សាក្នុងគ្រួសារ (អំពើហិង្សាពីដៃគូស្និទ្ធស្នាល)
- ការរំលោភសេពសន្ថវៈ និងអំពើហិង្សាផ្លូវភេទ
- ក្រុមស្ត្រីងាយរងគ្រោះ

**យុទ្ធសាស្ត្រ**

- ការបង្ការទប់ស្កាត់
- កិច្ចការពារផ្លូវច្បាប់ និងសេវាពហុវិស័យ
- ច្បាប់ និងគោលនយោបាយ
- ការពិនិត្យ តាមដាន និងវាយតម្លៃ

# ទិដ្ឋភាពទូទៅនៃផែនការសកម្មភាពជាតិលើកទី៣

**វិស័យយុទ្ធសាស្រ្តទី ១៖**
ការបង្ការទប់ស្កាត់

**វិស័យយុទ្ធសាស្រ្តទី ២៖**
កិច្ចការពារផ្លូវច្បាប់ និងសេវាកម្មពហុវិស័យ

**វិស័យយុទ្ធសាស្រ្តទី៣៖**
ការបង្កើត និងការអនុវត្តច្បាប់ និងគោលនយោបាយ

**វិស័យយុទ្ធសាស្រ្តទី៤៖**
ពិនិត្យតាមដាន និងវាយតម្លៃ

**ខ្លឹមសារដែលពាក់ព័ន្ធ ត្រូវបានបញ្ជ្រាបចូលនៅគ្រប់ចំណុច**

១. ស្រ្តីដែលមានតម្រូវការពិសេស

២. ការប្រែប្រួលអាកាសធាតុ

៣. បញ្ហាគោលនយោបាយ

៤. សន្តិភាពនិងសន្តិសុខសម្រាប់ស្រ្តី

៥. ស្រ្តីក្នុងវិស័យឯកជន

៦. អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី

# យុទ្ធសាស្ត្រទី១៖ ការបង្ការទប់ស្កាត់

គោលបំណង៖

ដើម្បីកាត់បន្ថយអំពើហិង្សាលើស្ត្រី និង ក្មេងស្រីតាមរយៈយុទ្ធសាស្ត្របង្ការទប់ស្កាត់ដែលមានការសម្របសម្រួលពហុវិស័យជាមួយ ក្រសួង និងស្ថាប័នដែលផ្តោតសំខាន់ទៅលើអ្នកពាក់ព័ន្ធសំខាន់ៗ និងនៅទីកន្លែងផ្សេងៗ ដើម្បីលើកកម្ពស់ការផ្លាស់ប្តូរជាវិជ្ជមាន។



# យុទ្ធសាស្ត្រទី២៖ កិច្ចការពារផ្លូវច្បាប់ និងសេវាពហុវិស័យ

គោលបំណង ៖

ដើម្បីបង្កើនការផ្តល់សេវា ដែលអាចទទួលយកបាន សមស្រប ការសម្របសម្រួលក្នុងការផ្តល់ប្រកបដោយគុណភាព និងការឆ្លើយតបផ្អែកតាមតម្រូវការផ្សេងៗរបស់ស្ត្រី និងក្មេងស្រីគ្រប់រូបដែលរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ។



# យុទ្ធសាស្ត្រទី៣៖ ការបង្កើត និងការអនុវត្តច្បាប់និងគោលនយោបាយ

គោលបំណង៖

ដើម្បីរៀបចំច្បាប់និងគោលនយោបាយ ដោយផ្អែកលើ ទស្សនៈយេនឌ័រ និងការពារសិទ្ធិស្ត្រី និងក្មេងស្រីជាជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងជនប្រព្រឹត្តត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។



# យុទ្ធសាស្ត្រទី៤៖ ពិនិត្យតាមដាន និងវាយតម្លៃ

គោលបំណង៖

ដើម្បីអភិវឌ្ឍប្រព័ន្ធមួយដែលមានលក្ខណៈ គ្រប់ជ្រុងជ្រោយ សម្រាប់ប្រមូល តាមដាន វិភាគ និងរាយការណ៍ទិន្នន័យអំពើហិង្សាលើស្ត្រី។

M&E
MONITORING & EVALUATION




# សេចក្តីព្រាងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០១៩ - ២០២៣

- *ក្រសួងស្ថាប័ន និង អង្គការសង្គមស៊ីវិលមួយចំនួនក៏បានរៀបចំផែនការយុទ្ធសាស្ត្រ និងកំណត់សូចនាកររៀងៗខ្លួន ក្នុងការទប់ស្កាត់ និងឆ្លើយតបអំពើហិង្សាលើស្ត្រី*

# ក្រមខ័ណ្ឌច្បាប់អន្តរជាតិ និងជាតិ















# អនុសញ្ញាស្ដីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ

- គឺជាសន្ធិសញ្ញាអន្តរជាតិ ដែលជាផ្នែកមួយនៃប្រព័ន្ធច្បាប់នៃសិទ្ធិមនុស្សនៃសហប្រជាជាតិ
- គឺជាកិច្ចព្រមព្រៀងអន្តរជាតិទូលំទូលាយមួយ មានបំណងចង់កែលំអស្ថានភាពស្ត្រី
- ជាទូទៅអនុសញ្ញា CEDAW លើកកម្ពស់ការសម្រេចបានស្មើគ្នានូវសិទ្ធិរបស់ស្ត្រី ក្នុងវិស័យ សេចដ្ឋកិច្ច សង្គម វប្បធម៌ នយោបាយ និងសិទ្ធិស៊ីវិល
- ត្រូវបានអនុម័តនៅក្នុងឆ្នាំ ១៩៧៩ តម្រូវឱ្យរដ្ឋាភិបាលថ្នាក់ជាតិចាត់រាល់វិធានការសមស្របទាំងឡាយ រួមទាំងការធ្វើច្បាប់ផងដែរ ដើម្បីធានាថាស្ត្រី ទទួលបានសិទ្ធិមនុស្ស និងសេរីភាព ជាមូលដ្ឋាន ដោយផ្អែកលើមូលដ្ឋានសមភាពជាមួយបុរស។

# អនុសញ្ញាស្តីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ

- គោលការណ៍ទាំង៣




| ១.សមភាព | ២.ការមិនរើសអើង | ៣.កាតព្វកិច្ច |
| --- | --- | --- |







# អនុសញ្ញាស្តីសិទ្ធិជនពិការ

- បានអនុម័តនៅថ្ងៃទី១២ ធ្នូ ២០០៦ ដោយអង្គការសហប្រជាជាតិ ដើម្បីលើស្ទួយ ការពារ និងធានថាជនពិការទទួលដោយពេញលេញនូវសិទ្ធិមនុស្ស សេរីភាព គោរពសេចក្តីថ្លៃថ្នូរដែលមានពីកំណើតពួកគេ
- ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៣ កម្ពុជាក្លាយជារដ្ឋភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពី សិទ្ធិជនពិការ
- អនុសញ្ញានេះ មាន៥០មាត្រា ដែលមានមាត្រាភាគច្រើនគឺស្របគ្នាទាំងស្រុងជាមួយនឹងច្បាប់ជាតិស្តីពី កិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ដែលប្រកាសឱ្យប្រើថ្ងៃទី០៣ ខែកក្កដា ២០០៩



# គោលការណ៍ទូទៅនៃអនុសញ្ញា

- ការគោរពសេចក្តីថ្លៃថ្នូរដែលមានពីកំណើត ស្វ័យភាពបុគ្គល រួមទាំងសេរីភាពក្នុងការជ្រើសរើសដោយខ្លួនឯងផ្ទាល់ និងឯករាជ្យភាពរបស់បុគ្គល
- ការមិនរើសអើង
- ការចូលរួមយ៉ាងពេញលេញ និងមានប្រសិទ្ធភាព និងដាក់បញ្ចូលទៅក្នុងសង្គម
- ឱកាសស្មើភាពគ្នា
- ការបង្កលក្ខណៈងាយស្រួល
- សមភាពរវាងបុរស និងស្ត្រី
- ការគោរពសមត្ថភាពរីកចម្រើនរបស់កុមារពិការ និងការគោរពសិទ្ធិកុមារពិការ ដើម្បីរក្សានូវអត្តសញ្ញាណរបស់ពួកគេ។

# អនុសញ្ញាស្តីពី សិទ្ធជនពិការ

មាត្រា ៦ ៖ ស្ត្រីពិការ

- រដ្ឋភាគីទទួលស្គាល់ថា ស្ត្រី និងកុមារីពិការ ងាយរងការរើសអើងច្រើនបែបយ៉ាងណាស់ ហើយចំពោះបញ្ហានេះ ត្រូវចាត់វិធានការនានា ដើម្បីធានាឱ្យពួកគេទទួលបានភាពស្មើគ្នា និងពេញលេញនូវសិទ្ធិមនុស្ស និង សេរីភាព
- រដ្ឋភាគីត្រូវចាត់រាល់វិធានការណ៍សមស្រប ដើម្បីធានាឱ្យស្ត្រីទទួលបាន ការអភិវឌ្ឍ វឌ្ឍនភាព និងការផ្តល់សិទ្ធិអំណាចឱ្យបានពេញលេញ ដើម្បីធានាឱ្យពួកគេ អនុវត្ត និងទទួលបាននូវសិទ្ធិមនុស្ស និង សេរីភាព

# យុទ្ធសាស្ត្រអ៊ីនឈាន់ ធ្វើឱ្យសិទ្ធក្លាយជាការពិត សម្រាប់ជនពិការប្រចាំតំបន់ អាស៊ី ប៉ាស៊ីហ្វិក

សំដៅពន្លឿនការអភិវឌ្ឍន៍រួមបញ្ចូលជនពិការ និងផ្តល់សច្ចាប័ន និងអនុវត្តអនុសញ្ញាស្តីពី សិទ្ធិជនពិការ

លក្ខណៈពិសេសជាសំខាន់ៗ ៖ គោលដៅ និងទិសដៅអ៊ីនឈាន់ មានលក្ខណៈកំណត់ពេល និងអាចវាស់បាន

ផ្អែកលើគោលការណ៍នានា របស់អនុសញ្ញាស្តីពី សិទ្ធិជនពិការ

សម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិកមួយដែលមានការដាក់បញ្ចូលពិការភាព និងភាពជាដៃគូ (ពហុផ្នែក ពហុភាគីដែលពាក់ព័ន្ធ)

**យុទ្ធសាស្ត្រអ៊ីឈាន់ មាន ១០ គោលដៅ ២៧ទិសដៅ និង៦២សូចនាករ**

# ក្របខ័ណ្ឌច្បាប់ ដើម្បីផ្តល់កិច្ចការពារដល់ស្ត្រី

## ច្បាប់របស់ប្រទេសកម្ពុជា

**រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា**

មាត្រា៣១ បានចែងថា ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នា ចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នា ទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ...

**ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ និងក្រមព្រហ្មទណ្ឌ ដែលចូល ជាធរមាននៅ ចុងឆ្នាំ ២០១០**

រាល់ទម្រង់ទាំងអស់នៃអំពើហិង្សាលើស្ត្រី និងកុមារ អាចផ្តន្ទាទោសបាន នៅក្រោមក្រមព្រហ្មទណ្ឌ ហើយរបៀបនៃការផ្តន្ទាទោសត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ

**ច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ...**

.ដើម្បីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការពារជនរងគ្រោះ និងពង្រឹងវប្បធម៌អហិង្សា និងភាពសុខដុមរមនា នៅក្នុងក្រុមគ្រួសារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។....

**ច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្ម ផ្លូវភេទ**

.បានហាមឃាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ តាមរូបភាពផ្សេងៗ ដូចជាអំពើពេស្យាចារ រូបភាព និងសម្ភារអាសអាភាស និងអំពើអាសជាដើម។

**ក្រមនីតិវិធី និងក្រមរដ្ឋប្បវេណី(២០០៧)**

.បានចែងថា សមាជិកគ្រួសារត្រូវគោរពសិទ្ធ និងសេរីភាពគ្នាទៅវិញទៅមក និងត្រូវទប់ស្កាត់មិនឱ្យមានអំពើហិង្សាក្នុងគ្រួសារ។

# យន្តការនៃការឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រ

**ថ្នាក់ជាតិ**

- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី
- ក្រសួងកិច្ចការនារី
- •ក្រុមការងារបច្ចេកទេសឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រ
- •ក្រុមការងារយេនឌ័រក្រសួង ស្ថាប័នពាក់ព័ន្ធ និងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រតាមវិស័យ

# ថ្នាក់ក្រោមជាតិ

**ក្រសួងកិច្ចការនារី**

**មន្ទីរកិច្ចការនារី**

**ការិយាល័យសង្គមកិច្ច និង សុខុមាលភាពសង្គម**

អ្នកទទួលបន្ទុក
កិច្ចការនារី និង កុមារ

**ក្រុមប្រឹក្សារាជធានី ខេត្ត៖**

- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និង កុមារ
- ក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ

**ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ៖**

- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និង កុមារ
- ក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ

**ក្រុមប្រឹក្សាឃុំ សង្កាត់៖**

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និង កុមារ

-អ្នកទទួលបន្ទុកកិច្ចការនារី និង កុមារ ជាសមាជិកអចិន្ត្រៃយ៍

-ភ្នាក់ងារពាក់ព័ន្ធ នៅថ្នាក់ឃុំ សង្កាត់ ជាសមាជិក